ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

SOCIAL PROTECTION IN CAMBODIA

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## សិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពី “ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម”

ក្រោមដំបូលនៃសន្តិភាព ដំណើរនៃការអភិវឌ្ឍរបស់កម្ពុជាបានបោះជំហានជាបន្តបន្ទាប់ និងមានការរីកចម្រើនប្រកបដោយមោទនភាព ព្រមទាំងទទួលបានការកោតសរសើរ និងការចាប់អារម្មណ៍ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ ដំណើរនៃការរីកចម្រើនជាលំដាប់ និងការអភិវឌ្ឍលើគ្រប់វិស័យ កើតចេញពីការដឹកនាំដ៏ត្រឹមត្រូវ និងការដាក់ចេញនូវក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រជាតិនានា ដែលក្នុងនោះរួមមានទាំងការដាក់ឱ្យអនុវត្ត **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥**។ ក្នុងគោលបំណងផ្សព្វផ្សាយ ឆ្លុះបញ្ចាំង និងបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តក្របខណ្ឌគោល-នយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ នេះ, ក្រុមប្រឹក្សាជាតិគាំពារសង្គមបានរៀបចំ សិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពី “**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម**” នៅថ្ងៃសុក្រ ៧រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានការចូលរួមពីតំណាងរបស់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។

សិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពី “**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម**” រយៈពេលពេញមួយថ្ងៃ ដែលត្រូវបានរៀបចំជាលើកទី៥ នេះ បានធ្វើការឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ក្រោមការដឹកនាំ និងសម្របសម្រួលអនុវត្តក្របខណ្ឌគោលនយោបាយ ដោយក្រុមប្រឹក្សាជាតិគាំពារសង្គមដែលមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន បាន និងកំពុងផ្តល់ការគាំពារដល់ប្រជាជនជាមួយអភិក្រមវដ្តជីវិត (life cycle)។ ជាក់ស្តែង ប្រជាជនក្រីក្រ និងងាយរងគ្រោះបាន និងកំពុងទទួលបាននូវការគាំពារសំខាន់ៗ ដូចជាការគាំពារសុខភាពមាតា និងទារក, ការផ្តល់ការព្យាបាលប្រជាជនក្រីក្រដែលមានជំងឺ ឬថែទាំសុខភាពនៅពេលសម្រាលកូន ការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដើម្បីជម្រុញ និងបង្កើនអាហារូបត្ថម្ភ និងការឧបត្ថម្ភសាច់ប្រាក់ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ជាដើម។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិសន្តិសុខសង្គម បេឡាជាតិអតីតយុទ្ធជន និងមូលនិធិជនពិការជាដើម ដើម្បីចូលរួមផ្តល់ការធានាសន្តិសុខប្រាក់ចំណូលសម្រាប់ប្រជាជន តាមមុខសញ្ញាពាក់ព័ន្ធនានា ដែលមានជាអាទិ៍ការផ្តល់តាវកាលិកសោធន ការថែទាំសុខភាព ហានិភ័យការងារ និងការគាំពារជនមានពិការភាព ផងដែរ។

អង្គសិក្ខាសាលាក៏បានកត់សម្គាល់ អំពីការវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដែលកំពុងប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងរង់ចាំលទ្ធផលនៃការវាយតម្លៃសមិទ្ធិកម្មនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនេះ នាពេលបន្ទាប់។

ជារួម អង្គសិក្ខាសាលាបានផ្តល់ឱកាសឱ្យមានការបញ្ចេញមតិយោបល់ និងដោះស្រាយចម្ងល់ផ្សេងៗ ដែលពាក់ព័ន្ធនឹងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងការអនុវត្តនាពេលកន្លងមក ដែលចូលរួមក្នុងកិច្ចខិតខំបន្ស៊ី ប្រមូលផ្តុំ ពង្រឹង និងពង្រីករបបសន្តិសុខសង្គម និងកម្មវិធីជំនួយសង្គម ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាព ក៏ដូចជាឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ធានាបាននូវក្របខណ្ឌអភិបាលកិច្ចល្អ និងបង្កើនប្រសិទ្ធភាពចំណាយថវិកាជាតិ។